# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបតំណាងមូលនិធិអាស៊ីប្រចាំកម្ពុជា



នៅព្រឹកថ្ងៃទី៣១ ខែ មីនា ឆ្នាំ២០១៦ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលជួបលោក **Silas Everett** តំណាងមូលនិធិអាស៊ីប្រចាំកម្ពុជា ដើម្បីពិភាក្សាការងារ នៅទីស្តីការក្រសួង ។



លោក **Silas Everett** តំណាងមូលនិធិអាស៊ីប្រចាំកម្ពុជា បានជម្រាបជូនពីគោលបំណងនៃជំនួបពិភាក្សា គឺដើម្បីជម្រាបជូនពីវឌ្ឍនភាពនៃការចងក្រងបញ្ជីកំណែទម្រង់របស់ក្រសួងនានានៅកម្ពុជា ក៏ដូចជាក្រសួងឧស្សាហកម្ម និង សិប្បកម្ម ។ លោក ប្រធានមូលនិធិអាស៊ី បានបញ្ជាក់ថាៈ តាមរយៈការសិក្សា ដោយមានការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាដែលជាអ្នកជំនាញផ្នែកសង្គមកិច្ច រដ្ឋបាល និងសេដ្ឋកិច្ចកាលពីចុងឆ្នាំ២០១៥ អង្គការមូលនិធិអាស៊ី បានធ្វើការបោះពុម្ពផ្សាយអត្ថបទវិចារណកថាមួយ ស្តីពី កំណែទម្រង់ធំៗចំនួនប្រាំ ប្រចាំឆ្នាំ២០១៥ នៅក្នុងគេហទំព័រមួយ នៃកាសែតភ្នំពេញប៉ុស្តិ៍ ។ លើសពីនេះទៅទៀត ក្នុងគោលបំណងដើម្បីផ្តល់ព័ត៌មានជាសាធារណៈទៅភាគីពាក់ព័ន្ធ រួមមានៈ រាជរដ្ឋាភិបាល ប្រជាពលរដ្ឋ វិស័យឯកជន និងស្ថាប័នសិក្សានានា អង្គការមូលនិធិអាស៊ី បានបង្កើតគេហទំព័រថ្មីមួយ ដើម្បីជាកន្លែងផ្ទុកព័ត៌មានស្តីពីកំណែទម្រង់ថ្មីៗរបស់ក្រសួង-ស្ថាប័ន នៅក្នុងប្រទេសកម្ពុជា ។ អង្គការមូលនិធិអាស៊ីនឹងអនុវត្តគំនិតផ្តួចផ្តើមនេះ នៅក្នុងឆ្នាំ២០១៦ ជាបន្តទៀត ដោយសង្ឃឹមថា ក្រសួងពាក់ព័ន្ធនានានឹងបន្តសហការបានកាន់តែប្រសើរលើការងារនេះ ។



ស្ថិតក្នុងឱកាសនោះដែរ លោក **Silas Everett** ក៏បានប្រគល់ឯកសារដកស្រង់ចេញពីគេហទំព័ររបស់ខ្លួន ដែលបានចុះផ្សាយពីកំណែទម្រង់នានារបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានដូចជា៖ការលើកកំពស់វិស័យសហគ្រាសខ្នាតតូច និងមធ្យម–ការអភិវឌ្ឍន៍ប្រព័ន្ធវាយតម្លៃទទួលស្គាល់ជាតិ–អភិវឌ្ឍន៍សៀវភៅមគ្គុទេសន៍អធិការកិច្ច – គំនិតផ្តួចផ្តើមឧស្សាហកម្មបៃតង–ការចុះបញ្ជីសហគ្រាសខ្នាតតូច និងមធ្យមតាមប្រព័ន្ធ Online –គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មពីឆ្នាំ ២០១៥–២០២៥–និងសេវាក្រោមដំបូលតែមួយជាដើម ។



មានប្រសាសន៍នាឱកាសនោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានវាយតម្លៃខ្ពស់ និងផ្តល់សារៈសំខាន់ចំពោះសកម្មភាពការងារនៃមូលនិធីអាស៊ីប្រចាំកម្ពុជា ស្តីពី គំនិតផ្តួចផ្តើម ក្នុងការចងក្រងបញ្ជីកំណែទម្រង់របស់ប្រទេសកម្ពុជា ដែលជាចំណុចគន្លឹះរបស់រាជរដ្ឋាភិបាល ក្នុងអភិវឌ្ឍន៍ប្រទេសប្រកបដោយប្រសិទ្ធិភាព និងតម្លាភាព ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានបញ្ជាក់ថា: រាល់កំណែទម្រង់ និងសកម្មភាពនានារបស់ក្រសួង ត្រូវបានផ្ញើជូនជារបាយការណ៍ទៅរាជរដ្ឋាភិបាល ។ ចំណែកមូលនិធីអាស៊ី ចាប់ពីពេលនេះទៅ អាចចូលទៅគេហទំព័ររបស់ក្រសួង ដើម្បីទទួលបានព័ត៌មាន ក៏ដូចជាកំណែទម្រង់នានា។ ក្នុងនោះ ឯកឧត្តមទេសរដ្ឋមន្ត្រី បានបញ្ជាក់ថា:កំណែទម្រង់ស៊ីជម្រៅរបស់ក្រសួងបច្ចុប្បន្នមានចំនួនច្រើនជាបន្តបន្ទាប់ ជាពិសេសលើវិស័យផ្គត់ផ្គង់ទឹកស្អាត–ស្តង់ដារ–មាត្រាសាស្ត្រ–វិស័យ SME –វាយតម្លៃទទួលស្គាល់ និងកម្មសិទ្ធិបញ្ញា ។ ល។

ក្នុងឱកាសនោះ តំណាងមូលនិធិអាស៊ី បានឯកភាពតាមសំណើរបស់ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ក្នុងការផ្តល់បញ្ជីសៀវភៅ ទាក់ទងនិងវិស័យបច្ចេកវិទ្យា–អេឡិចត្រូនិក–ការបង្កើតថ្មី និងវិទ្យាសាស្ត្រ ជាដើម សម្រាប់ជ្រើសរើសតំកល់ទុកក្នុងបណ្ណាល័យក្រសួង និងពិនិត្យលទ្ធភាពការសិក្សាស្រាវជ្រាវ ចងក្រងបញ្ជីសហគ្រាសខ្នាតតូច និងមធ្យម នៅកម្ពុជា ។